ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងសព្រហ្មទណ្ឌ

លេខ ១៣២៤

ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២០

សាលដីកា

លេខ ០៩ក្រIV-អប-

ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ បានប្រកាសបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍នាថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៤ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted]ច្ចិកា ភេទប្រុស អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់[redacted] ក្រុងភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្ទះជួល ផ្លូវលំ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (នៅលីវ) ឪពុកឈ្មោះ [redacted] គឹមសន (រស់) ម្តាយឈ្មោះ [redacted] សំអាត (រស់) ទោសពីមុន(គ្មាន) ។ ឃុំខ្លួនថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩ (ម១)។

-មេធាវី [redacted]ការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្លូវនរោត្តម កែវផ្លូវ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ០០ និង ០០ នាទី ជនរងគ្រោះជាជនជាតិបរទេសស្បែកខ្មៅ ភេទប្រុស អាយុប្រហែល ៣២ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម្នាក់ឯង មកដល់ចំណុចផ្លូវព្រះនរោត្តម កែងផ្លូវលេខ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ក៏ឈប់ម៉ូតូនិយាយទូរស័ព្ទ ស្រាប់តែឈ្មោះ [redacted] **វិច្ឆិកា** ជិះម៉ូតូមួយគ្រឿងម៉ាកឃ្លីក ពណ៌ក្រហម ពាក់ផ្លាកលេខភ្នំពេញ 1AQ-6877 ឌុបឈ្មោះ **ហៃ** ដោយឈ្មោះ **ហៃ** ជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះ តែត្រូវជនរងគ្រោះទាញមកវិញ ហើយបក្ខពួកឈ្មោះ **វី** ម្នាក់ទៀតជិះម៉ូតូមួយគ្រឿងជាអ្នកការពារពីក្រោយ ភ្លាមៗជនរងគ្រោះស្រែកឆោឡោ ស្របពេលកម្លាំងសមត្ថកិច្ចកំពុងល្បាតឃើញទាន់ក៏អន្តរាគមន៍ ឈានដល់ការឃាត់ខ្លួនឈ្មោះ [redacted] **វិច្ឆិកា** យកមកសាកសួរ ចំណែកឯឈ្មោះ **ហៃ** នឹងឈ្មោះ **វី** បានជិះម៉ូតូគេចខ្លួនបាត់តែម្តង។

-**បានឃើញ** ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** នៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងនាពេលសវនាការបានឆ្លើយមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ២៣ និង ០០នាទី ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកឃ្លីក ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1AQ-6877 ឌុបឈ្មោះ **ហៃ** ជិះមកដល់ផ្លូវ៤១ កែងផ្លូវលេខ១៥៤ ត្រង់ចំណុចភ្លើងស្តុប ក៏ឃើញជនរងគ្រោះជាជនជាតិស្បែកខ្មៅម្នាក់ ភេទប្រុស កំពុងឈប់និយាយទូរស័ព្ទ ខ្លួនក៏ជិះម៉ូតូទៅកៀក រួចឈ្មោះ **ហៃ** ជិះពីក្រោយធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរងគ្រោះ តែត្រូវជនរងគ្រោះទាញយកទូរស័ព្ទវិញ និងបានស្រែកឆោឡោឡើង ខ្លួនក៏បន្ថែមល្បឿនជិះគេចខ្លួន តែត្រូវសមត្ថកិច្ចប៉ុស្តិ៍នគរបាលផ្សារថ្មីទី៣ កំពុងល្បាតបានដេញចាប់ខ្លួន រួមទាំងដកហូតម៉ូតូមួយគ្រឿងខាងលើ រីឯបក្ខពួករបស់ខ្លួនឈ្មោះ **ហៃ** នឹងឈ្មោះ **វី** បានគេចខ្លួនបាត់អស់ហើយ ។ ចំពោះម៉ូតូខាងលើ គឺខ្លួនបានខ្ចីពីឈ្មោះ **តូច** នៅយប់កើតហេតុនេះទេ ។ ខ្លួនធ្លាប់ជាប់ពន្ធនាគាររយៈពេល ០១ឆ្នាំ ០៦ខែ ពីបទលួច និងទើបតែចេញពីពន្ធនាគារបានជិតមួយខែ ។

-**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧៣៥** ក្រ៩ (យ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោសលើឈ្មោះ [redacted] **វិច្ឆិកា** ភេទប្រុស អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤(បួនឆ្នាំ) ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្លូវនរោត្តម កែវផ្លូវ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.វត្ថុចាប់យករួមមាន ៖ ម៉ូតូម៉ាកហុងដាឃ្លីក (HONDA CLICK) ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1AQ-6877 (មិនប្រក្រតី,បាក់ក្បាំងមុខ,គ្មានសោ) ចំនួន០១គ្រឿង និងទូរស័ព្ទដៃម៉ាកសាំសុង (SAMSUNG) ពណ៌ស បិទស្កុតពណ៌ក្រហម (មិនដំណើរការ) ចំនួន០១គ្រឿង ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ **៧៤៨** ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៣៥ ក្រ៩ (យ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ **គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។**

-**បានឃើញ** របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០២០ ។

-**បានឃើញ** សេចក្តីសន្និដ្ឋានរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២០ ។

## នាពេលពិភាក្សាដេញដោល

-ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** (វត្តមាន)

-មេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-**ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេប**

-**ជនជាប់ចោទឈ្មោះ** [redacted] **វិច្ឆិកា** បានឆ្លើយនាពេលសវនាការថាៈ នៅថ្ងៃកើតហេតុ ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកឃ្លីក ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1AQ-6877 ឌុបឈ្មោះ **ហៃ** ជិះមកដល់ផ្លូវ ៤១ កែងផ្លូវលេខ១៥៤ ត្រង់ចំណុចភ្លើងស្តុប ក៏ឃើញបុរសជនជាតិស្បែកខ្មៅម្នាក់ កំពុងឈប់និយាយទូរស័ព្ទ ខ្លួនក៏ជិះម៉ូតូទៅកៀក រួចឈ្មោះ **ហៃ** ជិះពីក្រោយធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរងគ្រោះ តែត្រូវជនរងគ្រោះទាញយកទូរស័ព្ទវិញ និងបានស្រែកឆោឡោឡើង ហើយក៏ត្រូវសមត្ថកិច្ចប៉ុស្តិ៍នគរបាលផ្សារថ្មីទី៣ កំពុងល្បាតបានដេញចាប់ខ្លួន រួមទាំងដកហូតម៉ូតូមួយគ្រឿងខាងលើ រីឯបក្ខពួករបស់ខ្លួនឈ្មោះ **ហៃ** នឹងឈ្មោះ **វី** បានគេចខ្លួនបាត់អស់ហើយ ខ្លួនបានដឹងកំហុសហើយ ថ្ងៃក្រោយឈប់ប្រព្រឹត្តបែបនេះទៀតហើយ ។

-**តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ** បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] **វិច្ឆិកា** បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣ ហើយ ។ ឈ្មោះ [redacted] **វិច្ឆិកា** បានជិះម៉ូតូអែបផ្តល់លទ្ធភាពឲ្យបុគ្គលម្នាក់ទៀតឈ្មោះ **ហៃ** បានប្រព្រឹត្តបទល្មើសជាចេតនា និងជាសហចារីប្រព្រឹត្តបទល្មើស តែមិនបានសម្រេចផល មិនបានបង្ករបួសដល់ជនរងគ្រោះទេ ជាអង្គហេតុលួច ។ ហេតុនេះ តំណាងមហាអយ្យការស្នើសាលាឧទ្ធរណ៍កែប្រែបទចោទប្រកាន់ពីមាត្រា ៣៥៣ មាត្រា ៣៥៧ មកមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ និងសម្រេចទោសតាមច្បាប់។

-មេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនគ្មានចេតនាប្រព្រឹត្តបទល្មើសទេ នៅថ្ងៃកើតហេតុពេលត្រឡប់មក ផ្ទះវិញ កូនក្ដីខ្លួនបានជិះម៉ូតូអែបម៉ូតូមនុស្សប្រុសតាមបញ្ជារបស់មិត្តភ័ក្ដិរបស់ឈ្មោះ ហៃ ហើយស្រាប់តែឈ្មោះ ហៃ ឆក់ទូរស័ព្ទគេ តែមិនបានសម្រេច និងមិនមានរបួសដល់ជនរងគ្រោះទេ ។ ពេលគេស្រែកថា "ចោរៗ" ក៏ជិះរត់ និងបានប្រជាពលរដ្ឋ និងសមត្ថកិច្ចបានចាប់ឃាត់ខ្លួន ។ កូនក្ដីខ្លួនមានវ័យតិច បានសេពគប់មិត្តភ័ក្ដិមិនល្អ លង់ចាញ់បោកគេ បានប្រព្រឹត្តជាលើកដំបូង ហើយបានឆ្លើយសារភាពចាប់ពី ដំណាក់កាលដំបូង មិនបង្កការលំបាក ។ ហេតុដូចនេះ ស្នើសុំក្រុមប្រឹក្សាសម្រេចកែប្រែបទចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស ត្រង់មាត្រា ៣៥៣ មាត្រា ៣៥៧ មកបទ លួច ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញផ្ដន្ទាទោសតាមការប្ដឹងសុំរបស់កូនក្ដីខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា បាននិយាយសំដីចុងក្រោយថាៈ ស្នើសុំក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោសឲ្យខ្លួនបានជាប់ត្រឹម ២ឆ្នាំ។

**ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ**

**ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការការប្ដឹងសុំ**

**ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី**

**ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ**

**ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងរួច**

## សំអាងហេតុ

១/ បណ្ដឹងឧទ្ធរណ៍លេខ ៧៤៨ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០ របស់ពិរុទ្ធឈ្មោះ [redacted] វិច្ឆិកា បានធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។ ហេតុដូច្នេះ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៧៥ មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣។

២/ ជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា ត្រូវបានចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវនរោត្តម កែងផ្លូវលេខ ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយជនជាប់ចោទត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្ដន្ទាទោសតាមសាលក្រមព្រហ្មទណ្ឌលេខ ៧៣៥ ក្រ៩ (យ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០ ។ សាលក្រមនេះត្រូវបានពិរុទ្ធឈ្មោះ [redacted] វិច្ឆិកា ប្ដឹងឧទ្ធរណ៍ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល។

៣/ តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា បានឆ្លើយបញ្ជាក់មានន័យសង្ខេបថា នៅថ្ងៃកើតហេតុ ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកឃ្លីក ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1AQ-6877 ឌុបឈ្មោះ ហៃ ជិះមកដល់ផ្លូវ៤១ កែងផ្លូវលេខ១៥៤ ត្រង់ចំណុចភ្លើងស្តុប ក៏ឃើញបុរសជនជាតិស្បែក

ខ្មៅម្នាក់ កំពុងឈប់និយាយទូរស័ព្ទ ខ្លួនក៏ជិះម៉ូតូទៅកៀក រួចឈ្មោះ ហៃ ជិះពីក្រោយធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរងគ្រោះ តែត្រូវជនរងគ្រោះទាញយកទូរស័ព្ទវិញ និងបានស្រែកឆោឡោឡើង ហើយក៏ត្រូវសមត្ថកិច្ចប៉ុស្តិ៍នគរបាលផ្សារថ្មីទី៣ កំពុងល្បាតបានដេញចាប់ខ្លួន រួមទាំងដកហូតម៉ូតូមួយគ្រឿងខាងលើ រីឯបក្ខពួករបស់ខ្លួនឈ្មោះ ហៃ នឹងឈ្មោះ វី បានគេចខ្លួនបាត់អស់ហើយ ខ្លួនបានដឹងកំហុសហើយ ថ្ងៃក្រោយឈប់ប្រព្រឹត្តបែបនេះទៀតហើយ ។ សំណូមពរ ស្នើសុំក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោសឲ្យខ្លួនបានជាប់ត្រឹម ២ឆ្នាំ។

៤/ តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានកត់សម្គាល់ប្តឹងសុំថា បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] វិច្ឆិកា បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣ ហើយ ។ ឈ្មោះ [redacted] វិច្ឆិកា បានជិះម៉ូតូអែបផ្តល់លទ្ធភាពឲ្យបុគ្គលម្នាក់ទៀតឈ្មោះ ហៃ បានប្រព្រឹត្តបទ ល្មើសជាចេតនា និងជាសហចារីប្រព្រឹត្តបទល្មើស តែមិនបានសម្រេចផល បានបង្កគ្រោះថ្នាក់នៅទីសាធារណៈ មិនបានបង្ករបួសដល់ជនរងគ្រោះទេ ជាអង្គហេតុលួច ។ ហេតុនេះ តំណាងមហាអយ្យការស្នើសាលាឧទ្ធរណ៍កែប្រែបទចោទប្រកាន់ពីមាត្រា ៣៥៣ មាត្រា ៣៥៧ មកមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ និងសម្រេចទោសតាមច្បាប់។

៥/ តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា បានកត់សម្គាល់ការពារថា កូនក្តីខ្លួនគ្មានចេតនាប្រព្រឹត្តបទល្មើសទេ នៅថ្ងៃកើតហេតុពេលត្រឡប់មកផ្ទះវិញ កូនក្តីខ្លួនបានជិះម៉ូតូអែបម៉ូតូមនុស្សប្រុសតាមបញ្ជារបស់មិត្តភ័ក្ត្ររបស់ឈ្មោះ ហៃ ហើយស្រាប់តែឈ្មោះ ហៃ ឆក់ទូរស័ព្ទគេ តែមិនបានសម្រេច និងមិនមានរបួសដល់ជនរងគ្រោះទេ ។ ពេលគេស្រែកថា "ចោរៗ" ក៏ជិះរត់ និងបានប្រជាពលរដ្ឋ និងសមត្ថកិច្ចបានចាប់ឃាត់ខ្លួន ។ កូនក្តីខ្លួនមានវ័យតិច បានសេពគប់មិត្តមិនស្គាល់អត្តសញ្ញាណច្បាស់លាស់ លង់ចាញ់បោកគេ បានប្រព្រឹត្តជាលើកដំបូង ហើយបានឆ្លើយសារភាពចាប់ពី ដំណាក់កាលដំបូង មិនបង្កការលំបាក ។ ហេតុដូចនេះ ស្នើសុំក្រុមប្រឹក្សាសម្រេចកែប្រែបទចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស ត្រង់មាត្រា ៣៥៣ មាត្រា ៣៥៧ មកបទ លួច ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញផ្តន្ទាទោសតាមការប្តឹងសុំរបស់កូនក្តីខ្លួន។

៦/ ក្រោយពេលពិភាក្សាដេញដោល ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទឈ្មោះ [redacted] វិច្ឆិកា និងពិនិត្យឯកសារនានានៅក្នុងសំណុំរឿងរួច បានបញ្ជាក់ឲដឹងថា ជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា ពិតជាបានប្រព្រឹត្តអំពើលួចមែន បើធៀបទៅនឹងពាក្យបណ្តឹង អង្គហេតុ និងចម្លើយជនជាប់ចោទខ្លួនឯង ដែលអង្គហេតុនេះច្បាប់បានបញ្ញត្តិថា ជាបទល្មើសព្រហ្មទណ្ឌតម្រូវឲមានការទទួលខុសត្រូវ។

៧/ តាមរបាយការណ៍សំយោគលេខ ១៣៨/២០១៩របក ថ្ងៃព្រហស្បត្តិ៍ ១០រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ នៃស្នងការនគរបាលរាជធានីភ្នំពេញ បានសរសេរសន្និដ្ឋានថា ឈ្មោះ [redacted] **វិច្ឆិកា** ពិតជាបានប្រព្រឹត្តសកម្មភាពលួចមានស្ថានទម្ងន់ទោស(ឆក់ទូរស័ព្ទដៃ) ស្ថិតនៅចំណុចផ្លូវនរត្តម កែងផ្លូវលេខ ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ០០ និង ៣០នាទី ពិតប្រាកដមែន(ឯកសារលេខ ១/១)។

៨/ តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលើឈ្មោះ [redacted] **វិច្ឆិកា** ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំពោះមុខគណកម្មការចូលរួម និងជនជាប់សង្ស័យ បានបង្ហាញជាលទ្ធផលថា **វិជ្ជមាន** (មានសារធាតុញៀន) នៅក្នុងទឹកនោម(ឯកសារលេខ ១/១៣)។

៩/ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** បានដឹងពីចេតនារបស់ឈ្មោះ ហៃ ក្នុងការដកហូតដោយទុច្ចរិតនូវទូរស័ព្ទដៃរបស់ជនជាតិស្បែកខ្មៅ នៅទីសាធារណៈក្នុងបំណងយកជាកម្មសិទ្ធិរបស់ខ្លួន ជាបទល្មើសលួច ហើយត្រូវអនុវត្តទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ព្រោះថា សកម្មភាពរបស់ជនជាប់ចោទមិនបានប្រើអំពើហិង្សា និងកាប់គាស់ទំលុះទំលាយទេ។

១០/ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** បានឌុបជិះម៉ែបផ្តល់លទ្ធភាពឲ្យអ្នកជិះខាងក្រោយអាចឆក់យកទូរស័ព្ទគេបាន ជាចេតនាចូលរួមប្រព្រឹត្តបទល្មើស ហើយសកម្មភាពនេះបានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងសង្គម និងផលប្រយោជន៍ជនរងគ្រោះ ដែលច្បាប់បានហាមឃាត់ និងចាត់ជាបទល្មើសព្រហ្មទណ្ឌ ។ តែដោយសារជនជាប់ចោទធ្លាប់ជាប់ពន្ធនាគារម្តងរួចមកហើយ នៅតែមិនរាងចាល និងតេស្តទឹកនោមមានសារធាតុញៀនវិជ្ជមាន ក្រុមប្រឹក្សានឹងផ្តន្ទាទោសកម្រិតអតិបរមានៃមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១១/ ជាសរុបពីចំណុច ៣ ដល់ចំណុច ៩ នៃសំអាងហេតុខាងលើ ក្រុមប្រឹក្សាយល់ឃើញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** ជាអំពើល្មើសចូលជាតុផ្សំបទល្មើសព្រហ្មទណ្ឌពីបទ លួច ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវនរត្តម កែងផ្លូវលេខ ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

១២/ សេចក្តីវិនិច្ឆ័យចំណុច ១ ក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៧៣៥ ក្រ៩ (យ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីមានលក្ខណៈមិនត្រឹមត្រូវតាមអង្គហេតុ និងច្បាប់ទេ គប្បីបដិសេធចោល និងសម្រេចជាថ្មីវិញតាមការយល់ឃើញខាងលើដូចខាងក្រោម។

## ហេតុដូច្នេះ សាលាឧទ្ធរណ៍
## វិនិច្ឆ័យសេចក្តី

១/ ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៤៨ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០ របស់ពិរុទ្ធឈ្មោះ [redacted] **វិច្ឆិកា** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២/ កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] **វិច្ឆិកា** ពីបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទ លួច ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវនរោត្តម កែងផ្លូវលេខ ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ វិញ។

៣/ បដិសេធចំណុច ១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៧៣៥ក្រ៩(យ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់។

៤/ ផ្តន្ទាទោសឈ្មោះ [redacted] **វិច្ឆិកា** (អត្តសញ្ញាណមាននៅក្នុងសំណុំរឿងស្រាប់) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ពីបទ លួច ត្រង់មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវនរោត្តម កែងផ្លូវលេខ ១៥៤ ភូមិទី៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

៥/ បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបន្ត។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិឲ្យប្តឹងសាទុក្ខនៅក្នុងកំណត់ច្បាប់៕

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា: [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner